# ប៉ុស្តិ៍ ហិរញ្ញវត្ថុ និងធានារ៉ាប់រង

ថ្ងៃសុក្រ ទី៩ ខែតុលា ឆ្នាំ២០២០ | WWW.POSTKHMER.COM


## ខួបអនុស្សាវរីយ៍ទី៤១នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ

គិតចាប់តាំងពីថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ មក ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញអស់រយៈកាល៤១ឆ្នាំហើយ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព ស្ថិរភាព និងចីរភាព។ ទោះយ៉ាងណា សាធារណជនមួយចំនួននៅតែមានចម្ងល់ថា តើធនាគារជាតិនៃកម្ពុជាមានតួនាទីអ្វីខ្លះ ?

ធនាគារជាតិនៃកម្ពុជាគឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិ និងមានតួនាទីរក្សាស្ថិរភាពតម្លៃប្រាក់រៀល។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាជាអ្នករៀបចំតាក់តែង និងអនុវត្តគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា ជាអ្នកផ្តល់ និងដកហូតអាជ្ញាប័ណ្ណ តាក់តែងបទប្បញ្ញត្តិ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រចាំ ចេញផ្សាយរបាយការណ៍ និងព្រឹត្តបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យក្រៅប្រទេស ។ ជារួម ធនាគារជាតិនៃកម្ពុជាមានតួនាទីចម្បង៣៖

តួនាទីចម្បងទី១ របស់ធនាគារជាតិនៃកម្ពុជា គឺរក្សាស្ថិរភាពថ្លៃដែលបង្កបរិយាកាសអំណោយផលដល់ការវិនិយោគ ការប្រើប្រាស់ និងអាជីវកម្មនានា។ ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកនេះតម្លៃប្រាក់រៀលត្រូវបានរក្សានូវស្ថិរភាពល្អប្រសើរ ហើយបានរួមចំណែករក្សាអត្រាអតិផរណា ដែលជាសូចនាករបង្ហាញពីកម្រិតថ្លៃទំនិញប្រើប្រាស់ឱ្យស្ថិតនៅកម្រិតទាបប្រមាណ ២,៥% ជាមធ្យមប្រចាំឆ្នាំប៉ុណ្ណោះ ដែលជួយរក្សាបានអំណាចទិញនៃចំណូលរបស់ប្រជាពលរដ្ឋ។ នៅពេលដែលរូបិយវត្ថុជាតិបាត់បង់តម្លៃ ឬប្រែប្រួលថ្លៃខ្លាំងពេក វិនិយោគិនក្នុងស្រុក និងអន្តរជាតិនឹងបាត់បង់ទំនុកចិត្តលើសេដ្ឋកិច្ច និងការគ្រប់គ្រងរូបិយវត្ថុរបស់ប្រទេស។

តួនាទីចម្បងទី២ គឺត្រួតពិនិត្យប្រព័ន្ធធនាគារ។ ប្រព័ន្ធធនាគារដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកេណ្ឌប្រមូលប្រាក់សន្សំទៅផ្តល់ឱ្យអ្នកដែលមានតម្រូវការឥណទាន។ ការធ្វើអន្តរការីកម្មបែបនេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការគាំទ្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយ។

ក្រុមហ៊ុន សហគ្រាសនានា ដែលចង់ពង្រីកអាជីវកម្មរបស់ខ្លួន តែមិនមានដើមទុនគ្រប់គ្រាន់ អាចទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈឥណទាន។ ប៉ុន្តែឥណទាននេះអាចទទួលបានលុះត្រាតែសាធារណជនមានទំនុកចិត្តលើប្រព័ន្ធធនាគារ តាមរយៈការដាក់ប្រាក់សន្សំរបស់ពួកគាត់នៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាត្រូវធានាឱ្យបានថាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានលក្ខណៈគ្រប់គ្រាន់ស័ក្តិសមនឹងទទួលបានការជឿទុកចិត្តពីប្រជាពលរដ្ឋ តាមរយៈការត្រួតពិនិត្យជាប្រចាំ និងការធ្វើនិយតកម្មលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងនោះ។ បច្ចុប្បន្ន គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុបានបង្កើនចំនួនប្រាក់បញ្ញើសរុបដល់ប្រមាណ ១២៩,១ទ្រីលានរៀល និងឥណទានដល់ប្រមាណជា ១៤១,៨ទ្រីលានរៀល ទៅដល់សេដ្ឋកិច្ច។

ការរីកចម្រើនឥតឈប់ឈរនៃប្រព័ន្ធធនាគារបានអនុញ្ញាតឱ្យប្រជាជនកម្ពុជាជាច្រើនប្រើប្រាស់សេវាធនាគារកាន់តែសម្បូរបែប ដូចជា ឥណទានទិញផ្ទះ, ឥណទានបង់រំលស់សម្ភារប្រើប្រាស់, ការដាក់ប្រាក់បញ្ញើ, សេវាផ្ទេរ និងទូទាត់ប្រាក់,សេវាទូរស័ព្ទចល័ត កាន់តែងាយស្រួល និងគ្រប់ទីកន្លែង។

តួនាទីចម្បងទី៣ គឺការត្រួតពិនិត្យប្រព័ន្ធទូទាត់ តាមរយៈការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុជាបន្តបន្ទាប់ ដែលអនុញ្ញាតឱ្យប្រព័ន្ធធនាគារអាចដំណើរការបានដោយរលូន និងប្រកបដោយប្រសិទ្ធភាព។ សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក ជួយសម្រួលដល់ការទូទាត់ ការផ្ទេរប្រាក់ និងការដាក់ប្រាក់បញ្ញើ ជាដើម។

ជាមួយគ្នានេះប្រព័ន្ធទូទាត់រហ័សជួយសម្រួលដល់ប្រតិបត្តិការទូទាត់ទំនិញ និងសេវា និងការវិនិយោគទាំងក្នុងស្រុក និងអន្តរជាតិប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។ បច្ចុប្បន្ន ប្រព័ន្ធទូទាត់តាមទូរស័ព្ទចល័តនៅកម្ពុជាទទួលបាននូវអត្រានៃការប្រើប្រាស់លឿនជាងគេនៅក្នុងតំបន់ ហើយគណនីប្រព័ន្ធទូទាត់តាមទូរស័ព្ទចល័តបានកើនឡើងដល់ប្រមាណ ៨,២លានគណនី ដែលប្រជាពលរដ្ឋអាចទូទាត់ និងផ្ញើប្រាក់ទូទាំងប្រទេស និងឆ្លងដែនបានផងដែរ។ សម្រាប់ពលកររោងចក្រ ប្រព័ន្ធទូទាត់តាមទូរស័ព្ទចល័តនេះអាចជួយឱ្យពួកគាត់ផ្ទេរប្រាក់ទៅគ្រួសារនៅបណ្តាខេត្តនានាបានដោយងាយស្រួល ឆាប់រហ័ស និងចំណាយតិច។

សម្រាប់រាជរដ្ឋាភិបាល ប្រព័ន្ធទូទាត់បែបនេះ ត្រូវបានប្រើប្រាស់សម្រាប់ការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីបុគ្គលិកសាធារណៈ,ប្រមូលពន្ធ, បង់ថ្លៃសេវាសាធារណៈ ដូចជាទឹក ភ្លើងជាដើម ដែលជាលទ្ធផលអាចបង្កើនបាននូវតម្លាភាព និងប្រសិទ្ធភាពនៅក្នុងស្ថាប័នសាធារណៈឱ្យកាន់តែប្រសើរឡើង៕ ■

*អត្ថបទដោយ៖ ធនាគារជាតិនៃកម្ពុជា*







ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា បានឈ្នះពានរង្វាន់ និងលិខិតសរសើរជាច្រើនទាំងក្នុងនិងក្រៅប្រទេស នៅក្នុងរយៈពេលជាង៨ឆ្នាំកន្លងមកនេះ។

# ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា ឈ្នះពានរង្វាន់អន្តរជាតិក្នុងនាមជា «ស្ថាប័នការងារឈានមុខគេនៅអាស៊ី»



លោក Justin Helferich អគ្គនាយកប្រតិបត្តិ និងនាយកចាត់ការទូទៅនៃក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា។

ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិដំបូងបំផុតនៅកម្ពុជា បានឈ្នះពានរង្វាន់អន្តរជាតិក្នុងនាមជា «ស្ថាប័នការងារឈានមុខគេនៅអាស៊ី» ពីស្ថាប័ន Asia Corporate Excellence & Sustainability (ACES) កាលពីពេលថ្មីៗនេះ។ នេះគឺជាឆ្នាំទី ២ ហើយដែលក្រុមហ៊ុនត្រូវបានទទួលស្គាល់ក្នុងកម្មវិធីពានរង្វាន់លំដាប់អន្តរជាតិនេះបន្ទាប់ពីបានឈ្នះពានរង្វាន់ «ក្រុមហ៊ុនឈានមុខប្រចាំតំបន់អាស៊ីក្នុងសកម្មភាពគាំទ្រសហគមន៍» កាលពីឆ្នាំមុន។ មេនូឡាយហ្វ៍ ខេមបូឌា ជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនចំនួន៦នៅអាស៊ី និងជាក្រុមហ៊ុនតែមួយគត់ពីប្រទេសកម្ពុជាដែលទទួលបានពានកិត្តិយសនេះ។

ពានរង្វាន់នេះទទួលស្គាល់ស្ថាប័នដែលប្រកាន់ខ្ជាប់យុទ្ធសាស្ត្រដែលយកបុគ្គលិកជាគោល និងបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ ក្នុងការលើកកម្ពស់ និងអភិវឌ្ឍសមត្ថភាពបុគ្គលិក។ ការទទួលស្គាល់នេះដើរស្របគ្នាយ៉ាងល្អឥតខ្ចោះទៅនឹងបេសកកម្មរបស់ក្រុមហ៊ុន មេនូឡាយហ្វ៍ ក្នុងការជួយប្រជាជន ក៏ដូចជាបុគ្គលិកយើងឲ្យធ្វើការសម្រេចចិត្តបានកាន់តែងាយស្រួល និងជីវិតកាន់តែប្រសើរ។

លោក Justin Helferich អគ្គនាយកប្រតិបត្តិ និងនាយកចាត់ការទូទៅរបស់ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា បានមានប្រសាសន៍ថា៖ «នៅក្រុមហ៊ុន មេនូឡាយហ្វ៍ យើងមានឆន្ទៈរួមគ្នាជាសកលក្នុងការទទួលយកភាពចម្រុះដើម្បីបង្កើតបរិយាកាសការងារដែលប្រកបដោយភាពសម្បូរបែបចម្រុះគ្នា និងការរួបរួមគ្នាមួយ ដែលបុគ្គលិកទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យធ្វើការទៅតាមជំនាញរបស់ខ្លួនដោយអស់ពីសមត្ថភាព។ ការធ្វើបែបនេះផ្តល់ឱកាសឲ្យពួកគាត់រីកចម្រើនលូតលាស់ទាំងលើសមត្ថភាពផ្ទាល់ខ្លួន និងវិជ្ជាជីវៈក្នុងការបម្រើអតិថិជន ដៃគូអាជីវកម្ម និងសហគមន៍របស់យើងបានយ៉ាងល្អបំផុត»។

លោកបានបន្ថែមទៀតថា៖«យើងមានកិត្តិយសណាស់ដែលក្រុមហ៊ុនយើងទទួលបានពានរង្វាន់ដ៏មានកិត្យានុភាពនេះ។ ការទទួលស្គាល់នេះនឹងជំរុញយើងបន្ថែមទៀតក្នុងការបន្តនាំយកនូវបទពិសោធ កាន់តែល្អឥតខ្ចោះជូនបុគ្គលិករបស់យើងដែលជាលទ្ធផលអនុញ្ញាតឲ្យយើងជួយកសាងអនាគតហិរញ្ញវត្ថុកាន់តែរឹងមាំ និងល្អប្រសើរជូនអតិថិជន។ យើងជឿជាក់ថា ភាពរីករាយរបស់បុគ្គលិកនឹងនាំមកនូវភាពរីករាយដល់អតិថិជន»។

លោកស្រី Shanggari Balakrishnan អគ្គនាយិកាប្រតិបត្តិរបស់ MORS Group ដែលជាអ្នករៀបចំកម្មវិធីពានរង្វាន់នេះមានប្រសាសន៍ថា៖«ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា យកចិត្តទុកដាក់ និងទទួលយកនូវរាល់ការបញ្ចេញមតិយោបល់របស់បុគ្គលិក វាយតម្លៃលើការចូលរួមរបស់បុគ្គលិក និងផ្តល់នូវអត្ថប្រយោជន៍ការងារដែលមានការប្រកួតប្រជែង។ យុទ្ធសាស្ត្រនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណតម្លៃរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយនេះ»។

លោក Jayanthi Desan សមាជិកមួយរូបរបស់គណៈកម្មការវាយតម្លៃក្នុងកម្មវិធីពានរង្វាន់ ACES បានមានប្រសាសន៍ថា៖ «ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា ផ្តោតសំខាន់លើការផ្តល់សិទ្ធិស្មើគ្នាក្នុងកន្លែងការងារក៏ដូចជាខិតខំប្រឹងប្រែងផ្តល់ការយកចិត្តទុកដាក់ដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ ហើយសកម្មភាពទាំងអស់នេះបានធ្វើឲ្យ មេនូឡាយហ្វ៍ ខេមបូឌា ក្លាយជាស្ថាប័នដែលមានលក្ខណៈពិសេសស័ក្តិសមនឹងទទួលបានការទទួលស្គាល់នេះ។»

ក្នុងរយៈពេលជាង ៨ ឆ្នាំកន្លងមកនេះ ក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា បានទទួលពានរង្វាន់កិត្តិយស និងលិខិតសរសើរជាច្រើន ទាំងក្នុងនិងក្រៅប្រទេសរួមមាន៖

- ពានរង្វាន់ទំនាក់ទំនងល្អជាមួយអតិថិជនប្រចាំឆ្នាំ (២០១៧ ដល់ ២០១៩) ទីក្រុង ហុងកុង
- ពានរង្វាន់កិត្តិនាមក្រុមហ៊ុនឆ្នើមប្រចាំឆ្នាំ (២០១៨ ដល់ ២០១៩) ទីក្រុង ហុងកុង
- ពានរង្វាន់ភាពជាអ្នកដឹកនាំសកម្មភាពសង្គមប្រចាំឆ្នាំ (២០១៧ ដល់ ២០១៩) ទីក្រុង ហុងកុង
- ពានរង្វាន់កិត្តិនាមជាក្រុមហ៊ុនឆ្នើម (២០១៩ ដល់ ២០២០) ប្រទេសថៃ
- លិខិតសរសើរពីគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៃក្រសួងសាធារណការ និងដឹកជញ្ជូន (២០១៨ ដល់ ២០២០)៕ ■

# IBF និងសាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គុន ចុះ MoU ដើម្បីផ្សារភ្ជាប់គម្លាត

វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) កាលពីថ្ងៃពុធបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គុនដើម្បីលើកកម្ពស់កិច្ចសហការផ្សារភ្ជាប់គម្លាតជំនាញរវាងកម្មវិធីសិក្សារបស់ស្ថាប័នអប់រំ និងតម្រូវការនៃឧស្សាហកម្មធនាគារ។

ពិធីចុះហត្ថលេខានេះ ត្រូវបានធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងទទួលបានការអញ្ជើញផ្តល់កិត្តិយសដោយលោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជា។

ក្នុងនោះមានការចូលរួមពីក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់នៃវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ(IBF) និងសាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គុន ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃសមាគមធនាគារនៅកម្ពុជា(ABC)និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)។

តាមរយៈ MoU នេះវិទ្យាស្ថាន IBF និងសាកលវិទ្យាល័យ ផារ៉ាហ្គុននឹងសហការគ្នាក្នុងការផ្តួចផ្តើមគំនិតផ្សេងៗដើម្បីផ្សារភ្ជាប់គម្លាតរវាងតម្រូវការជំនាញដែលកំពុងវិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃវិស័យឧស្សាហកម្មធនាគារ និងអ្នកដែលបណ្តុះបណ្តាលដោយប្រព័ន្ធអប់រំឧត្តមសិក្សា។

ឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំបានមានប្រសាសន៍ថា៖«កម្មវិធីអប់រំឧត្តមសិក្សានៅកម្ពុជាបានពង្រីកយ៉ាងឆាប់រហ័សដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកំណើននៅក្នុងវិស័យផ្សេងៗ ប៉ុន្តែកំណើននេះមិនមានភាពស៊ីចង្វាក់គ្នាជាមួយនឹងតម្រូវការនៃវិស័យឧស្សាហកម្មនោះទេ ដោយសារតែមិនមានកិច្ចសហការរវាងអង្គភាពទាំង២»។

«ខ្ញុំសូមអបអរសាទរគំនិតផ្តួចផ្តើមនេះ ដែលដឹកនាំដោយ IBF និងមានការគាំទ្រពីសំណាក់ ABC និង CMA ក៏ដូចជាកិច្ចសហប្រតិបត្តិការជាវិជ្ជមានរបស់ Paragon.U ដើម្បីចូលរួមក្នុងការសហការគ្នាជាផ្លូវការនេះ។ ខ្ញុំទន្ទឹងរង់ចាំមើលការខិតខំប្រឹងប្រែងរួមគ្នាជាច្រើនទៀតរួមទាំងសាកលវិទ្យាល័យសាធារណៈក្នុងស្រុករបស់យើង»។

លោក ជា កញ្ញារិទ្ធិ អ្នកគ្រប់គ្រងទូទៅនៃវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា៖« គោលបំណងនៃ MoU នេះគឺដើម្បីផ្សារភ្ជាប់គម្លាត ទាក់ទងនឹងសមត្ថភាពរវាងតម្រូវការឧស្សាហកម្មនេះ និងកម្មវិធីរបស់ស្ថាប័នអប់រំ ដើម្បីធ្វើឱ្យប្រាកដថា ស្ថាប័នអប់រំ បណ្តុះបណ្តាលបាននិស្សិតស្របតាមតម្រូវការរបស់ឧស្សាហកម្មធនាគារ»។



**លោក ដេត សុខឧត្តម (ឆ្វេង) និងលោក ជា កញ្ញារិទ្ធិ ចាប់ដៃគ្នាបន្ទាប់ពីចុះ MoU ។** ហ៊ាន រង្សី

លោកជំទាវ ជា សិរី មានប្រសាសន៍ថា៖«នៅក្នុងការកែលម្អការអប់រំមនុស្សគ្រប់គ្នាគួរតែដើរតួសំខាន់មួយជាពិសេសក្នុងវិស័យឧស្សាហកម្ម។ ធនាគារជាតិនៃកម្ពុជាបានធ្វើការជាមួយឧស្សាហកម្មដើម្បីផ្តួចផ្តើមវិទ្យាស្ថាន IBF និងរីករាយដែលបានឃើញឥទ្ធិពលវិជ្ជមានរបស់ IBF ទៅលើប្រព័ន្ធរួមនៃការកសាងសមត្ថភាពខាងធនាគារនៃនិស្សិតបញ្ចប់ការសិក្សា ទៅជាអ្នកជំនាញធនាគាររួមគ្នាឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើចំណេះដឹង និងបម្រើគោលដំណងឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងការរីកចម្រើនប្រកបដោយចីរភាព»។

លោកបណ្ឌិត អ៊ិន ចាន់នី ប្រធានសមាគមធនាគារនៅកម្ពុជា មានប្រសាសន៍ថា៖«អនុស្សរណៈយោគយល់គ្នានៅថ្ងៃនេះ គឺជានិមិត្តសញ្ញានៃព្រឹត្តិការណ៍ដ៏សំខាន់មួយដែលយើងអាចទន្ទឹងរង់ចាំនូវការខិតខំប្រឹងប្រែងបន្ថែម និងបន្តទៅមុខទៀតឥតឈប់ឈរ សម្រាប់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីរៀបចំ និងកែលម្អកម្មវិធីសិក្សាឡើងវិញ ជាពិសេសទាក់ទងនឹងតម្រូវការវិស័យធនាគារ និងធម្មជាតិដែលមានភាពប្រែប្រួលនៃពិភពធុរកិច្ចជំនួញ»។

ឯកឧត្តម អ៊ាង សុផល្លែត ប្រធានកិត្តិយសនៃសាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គុន មានប្រសាសន៍ថា៖«ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ រវាងសាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គុន និងវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ គឺជាសក្ខីភាពដ៏ល្អមួយនៃការប្តេជ្ញាចិត្តរបស់សាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គុន ក្នុងការកសាងភាពជាដៃគូរវាងសាកលវិទ្យាល័យ និងវិស័យឧស្សាហកម្ម»។

អនុស្សរណៈនៃការយោគយល់នេះផ្តល់ជូននិស្សិត និងសមាជិកមហាវិទ្យាល័យនៃសាកលវិទ្យាល័យនូវឱកាសដើម្បីអភិវឌ្ឍ បង្កើនជំនាញ ចំណេះដឹង និងបណ្តាញរបស់ពួកគេនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ៕■



# អតិថិជនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្នើសុំរៀបចំឥណទានឡើងវិញមានការថយចុះ

ចំនួនអ្នកទទួលកម្ចីខ្នាតតូចដែលរងផលប៉ះពាល់ដោយជំងឺកូវីដ១៩ មានការថយចុះក្នុងការស្នើសុំពន្យារពេលសងប្រាក់កម្ចី។

លោក ផល វ៉ាន់ឌី នាយកប្រតិបត្តិសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា និន្នាការបច្ចុប្បន្នពិតជា "សញ្ញាល្អ" ដោយសារការជះឥទ្ធិពលរបស់កូវីដ ១៩ ទៅលើសេដ្ឋកិច្ចកំពុងធ្លាក់ចុះ។

"សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាកត់សម្គាល់ឃើញថា ការកើនឡើងនៃការស្នើសុំរៀបចំប្រាក់កម្ចីឡើងវិញរបស់អតិថិជននៅខែមេសា និងឧសភា ដែលមានចំនួន២០ ០០០ នាក់ រៀងរាល់សប្តាហ៍ ប៉ុន្តែក្រោយមកបានធ្លាក់ចុះមកដល់ត្រឹម ១០ ០០០ នាក់ក្នុងខែមិថុនានិងកក្កដា។ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ចំនួនការស្នើសុំបានធ្លាក់ចុះមកត្រឹមប្រមាណ ១ ០០០ ក្នុង១សប្តាហ៍ប៉ុណ្ណោះ។

"នេះពិតជាសញ្ញាល្អដែលបង្ហាញថាផលប៉ះពាល់ ដោយសារកូវីដ ១៩ កំពុងថយចុះ ហើយសេដ្ឋកិច្ចកំពុងងើបឡើងវិញ។ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា កំពុងពិភាក្សាជាមួយសមាជិក និងអ្នកពាក់ព័ន្ធដើម្បីពិនិត្យមើលលទ្ធភាពនៃការបន្តការរៀបចំឥណទានឡើងវិញរហូតដល់ឆ្នាំ២០២១ ខណៈអតិថិជនមួយចំនួនមកពីវិស័យទេសចរណ៍នៅតែរងផលប៉ះពាល់គួរឱ្យកត់សម្គាល់។

គិតត្រឹមខែកញ្ញា អ្នកទទួលប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុជាង ២៧០ ០០០ នាក់បានដាក់ស្នើសុំធ្វើការរៀបចំកម្ចីឡើងវិញពីគ្រឹះស្ថានចំនួន ១០៣ ស្ថាប័នដែលជាសមាជិក សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ លោកថា សំណើសរុបចំនួន ២៦០ ០០០ ឬ ៩៤ ភាគរយ ត្រូវបានអនុម័តឱ្យរៀបចំឡើងវិញ ជាមួយនឹងប្រាក់កម្ចីចំនួន ១ ២៧០ លានដុល្លារ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានផ្តល់ប្រាក់កម្ចីដែលមានតម្លៃ ៧ ២០០ លានដុល្លារ ដល់អតិថិជនចំនួន ២,១ លាននាក់ ខណៈដែលអ្នកដាក់ប្រាក់បញ្ញើចំនួន ២,៨ លាននាក់ ដែលមានទឹកប្រាក់បញ្ញើចំនួន ៣,៨ ពាន់លានដុល្លារ នៅតាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើចំនួន ៦ ក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ ១៩ ប្រាក់កម្ចីមិនដំណើរការ (NPL) នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងពី ១,៥ ភាគរយ ដល់ ២,៥ ភាគរយ ដោយចាប់កើនឡើងក្នុងខែមីនា និងបានឡើងដល់



លោក ផល វ៉ាន់ឌី នាយកប្រតិបត្តិសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

កំពូលនៅខែឧសភា ប៉ុន្តែបានថយចុះបន្តិចម្តងៗ នៅខែបន្តបន្ទាប់។

នៅក្នុងខែសីហា ប្រាក់កម្ចីមិនដំណើរការមានចំនួន ២,៧ ភាគរយ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ខណៈវិស័យធនាគារនិងហិរញ្ញវត្ថុទាំងមូលមានចំនួន ២,៣ ភាគរយ។ ទោះយ៉ាងណាកម្រិតប្រាក់កម្ចីមិនដំណើរការត្រូវបានគេចាត់ទុកថាមាននិរន្តរភាពផ្អែកតាមស្តង់ដាសកល។ នេះបើយោងតាមតួលេខរបស់សមាគម។

ដូចគ្នានឹងវិស័យផ្សេងទៀតដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏រងផលប៉ះពាល់ពីជំងឺរាតត្បាតផងដែរដោយត្រូវទទួល បន្ទុកជាមួយនឹងការកើនឡើងថ្លៃដើមប្រតិបត្តិការ និងការធ្លាក់ចុះនៃប្រាក់ចំណូលដោយសារតម្រូវការប្រាក់កម្ចីបានធ្លាក់ចុះ។

បើក្រឡេកមើលភាពវិជ្ជមានវិញ ជំងឺរាតត្បាតនេះគ្រាន់តែជាវិញ្ញាសាសាកល្បងមួយទៀតដើម្បីបង្ហាញពីភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ក្នុងគ្រាដ៏លំបាកនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនត្រឹមតែអាចទប់ទល់ ប៉ះពាល់ ហើយនៅបន្តដំណើរការបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកៀរគរធនធានរបស់ខ្លួនទៅជួយដល់អតិថិជន និងសហគមន៍ដែលរងផលប៉ះពាល់។

សមាគមនិងសមាជិករបស់ខ្លួនបានចាត់វិធានការយ៉ាងសកម្ម ដោយរៀបចំយុទ្ធសាស្ត្រស្តារអាជីវកម្ម ដូចជាផែនការត្រៀមអាជីវកម្មពេលមានហានិភ័យ រួមទាំងផែនការបន្តអាជីវកម្មចាប់តាំងពីខែមករា ដើម្បីដឹកនាំវិស័យហិរញ្ញវត្ថុ នៅពេលដែលបានរំខានដល់ប្រតិបត្តិការអាជីវកម្មដោយសារការរាលដាលនៃជំងឺកូវីដ១៩ ។

សមាជិក សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានត្រៀមទប់ទល់ផលប៉ះពាល់ដែលធ្ងន់ធ្ងរជាងនេះ។ ប្រសិនបើ អតិថិជនណាម្នាក់របស់គ្រឹះស្ថានដែលជាសមាជិកសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា រងផលប៉ះពាល់ដោយជំងឺកូវីដ១៩ គាត់អាចស្នើសុំធ្វើការរៀបចំឥណទានឡើងវិញបាន ប្រសិនបើគាត់មិនទាន់មានលទ្ធភាពសងត្រឡប់ជាធម្មតា។ សមាជិករបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ជឿជាក់ថា ជោគជ័យរបស់អតិថិជន ទើបជាភាពជោគជ័យពិតប្រាកដរបស់គ្រឹះស្ថាន។

"សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាកំពុងចូលរួមយ៉ាងសកម្មជាមួយសមាជិកទាំងអស់របស់ខ្លួន, ដូចជាធនាគារជាតិនៃកម្ពុជា និងការិយាល័យឥណទានកម្ពុជា ដើម្បីតាមដានដោយផ្ទាល់ជាក់ស្តែងនូវការប្រែប្រួលនៃទីផ្សារឥណទាន ដើម្បីជួយឱ្យវិស័យនេះអាចទប់ទល់ និងកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចពីការរីករាលដាលនៃជំងឺកូវីដ១៩ មកលើអតិថិជនមីក្រូហិរញ្ញវត្ថុ។

លោកវ៉ាន់ឌី បានមានប្រសាសន៍ថា "ប្រាក់បម្រុងទុកក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងធំៗទាំង១០ នៅតែភាពរឹងមាំ"។ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ហៅកាត់ថា CMA មានសមាជិករួមមានធនាគារចំនួន ៤, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៧៦, គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ១១ និងប្រតិបត្តិករឥណទានជនបទចំនួន ១២៕ ■

# វិទ្យាស្ថាន CamEd បណ្តុះបណ្តាលនិស្សិតសម្រាប់ពិភពហិរញ្ញវត្ថុ

កាលពីឆ្នាំមុន ៩៦ភាគរយនៃនិស្សិតចំនួន៣១៣នាក់របស់វិទ្យាស្ថាន CamEd Business School ដែលបានបញ្ចប់បរិញ្ញាបត្រគណនេយ្យនិងហិរញ្ញវត្ថុ ទទួលបានការងារធ្វើ ខណៈនៅសល់៤%ទៀត អ្នកខ្លះធ្វើអាជីវកម្មផ្ទាល់ខ្លួន អាជីវកម្មគ្រួសារ ហើយមួយចំនួនទៀតនៅបន្តការសិក្សារបស់ពួកគេ។

សម្រាប់និស្សិតដែលបញ្ចប់ការសិក្សាថ្មីៗ ពួកគេទទួលបានការងារយ៉ាងឆាប់រហ័សនៅក្នុងទីផ្សារការងារដ៏ចង្អៀត ដែលនេះជាមោទនភាពមួយសម្រាប់វិទ្យាស្ថានCamEd។

តួលេខនេះបានបង្ហាញនូវលទ្ធផលដ៏គួរឱ្យកត់សម្គាល់ចំនួន២ គឺតម្រូវការកើនឡើងនៅក្នុងវិស័យហិរញ្ញវត្ថុសម្រាប់បុគ្គលិកដែលមានទេពកោសល្យ និងសមត្ថភាពរបស់វិទ្យាស្ថាន CamEd ដែលបានបណ្តុះបណ្តាលនិស្សិតប្រកបដោយគុណភាពសម្រាប់វិជ្ជាជីវៈគណនេយ្យ។

និស្សិតដែលបញ្ចប់ការសិក្សានៅ CamEd នឹងទទួលបានការងារយ៉ាងឆាប់រហ័សពីធនាគារ ក្រុមហ៊ុនវិនិយោគនិងក្រុមហ៊ុនគណនេយ្យករធំៗ ដូចជា PwC, KPMG, Deloitte និង Ernst & Young ដែលផ្តល់នូវឱកាសដ៏អស្ចារ្យសម្រាប់ការរីកចម្រើនអាជីពបន្តទៀត។



លោក Casey Barnett នាយកវិទ្យាស្ថាន CamEd។

លោក Casey Barnett នាយកវិទ្យាស្ថាន CamEd បានឲ្យភ្នំពេញប៉ុស្តិ៍ដឹងថា៖«នៅ CamEd ជារៀងរាល់ឆ្នាំការបង្រៀនជំនាញគណនេយ្យនិងហិរញ្ញវត្ថុរបស់យើងកាន់តែល្អប្រសើរឡើង។ នេះបានក្លាយជាគុណសម្បត្តិដ៏ធំបំផុតរបស់យើង ជាកម្លាំងដ៏ពិតប្រាកដរបស់យើង ហើយយើងនាំមកនូវគុណតម្លៃដ៏អស្ចារ្យដល់និស្សិត។ ដូច្នេះនេះជាទិសដៅដែលយើងកំពុងអនុវត្ត»។

រយៈពេល ២០ឆ្នាំកន្លងមកនេះ វិទ្យាស្ថាន CamEd ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០០ បានបណ្តុះបណ្តាលនិស្សិតជាច្រើនឲ្យមានសមត្ថភាព និងជំនាញខ្ពស់បំផុតនៅក្នុងវិស័យហិរញ្ញវត្ថុនិងគណនេយ្យ។

វគ្គសិក្សាដ៏មានប្រជាប្រិយបំផុតមួយរបស់ CamEd គឺបរិញ្ញាបត្រគណនេយ្យនិងហិរញ្ញវត្ថុដូចថ្នាក់គណនេយ្យករជំនាញ (ACCA) និងសញ្ញាបត្រជំនាញអ្នកបច្ចេកទេសផ្នែកគណនេយ្យ (CAT)។ វគ្គសិក្សាជំនាញទាំងនេះជួយបើកទ្វារសម្រាប់អាជីពការងារដ៏ល្អនៅក្នុងពិភពគណនេយ្យនិងហិរញ្ញវត្ថុ។

«ខ្ញុំគិតថាបច្ចុប្បន្នមានយុវជនជាច្រើនពួកគាត់ចង់ជោគជ័យក្នុងអាជីវកម្មហើយគណនេយ្យគឺពិតជាគ្រឹះដ៏រឹងមាំ។ នៅពេលអ្នកមានគ្រឹះគណនេយ្យរឹងមាំអ្នកអាចធ្វើការនៅក្នុងអាជីវកម្មណាមួយក៏បាន ពីព្រោះគ្រប់អាជីវកម្មគឺត្រូវការគណនេយ្យ»។

លោក Barnett បានបន្ថែមថា៖ «បរិញ្ញាបត្រគណនេយ្យនិងហិរញ្ញវត្ថុគឺនៅតែជាគន្លឹះដ៏សំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា»។

បរិញ្ញាបត្រគណនេយ្យនិងហិរញ្ញវត្ថុ (Honours) គឺមានរយៈពេល៤ឆ្នាំ។ ទន្ទឹមនឹងនេះដែរ និស្សិតក៏អាចទទួលបានសញ្ញាបត្រជំនាញអ្នកបច្ចេកទេសគណនេយ្យ (CAT)ហើយថែមទាំងអាចបន្តសិក្សាថ្នាក់គណនេយ្យករជំនាញ (ACCA)បានទៀតផង។

ស្តង់ដាអន្តរជាតិទាំងនេះនិងអនុលោមតាមតម្រូវការរបស់សហព័ន្ធគណនេយ្យករអន្តរជាតិ ក្រសួងអប់រំ យុវជននិងកីឡា និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

វគ្គសិក្សាទាំងនេះផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៅក្នុងវិស័យគណនេយ្យ ដែលជួយនិស្សិតដែលបញ្ចប់ការសិក្សាឲ្យបានយល់កាន់តែស៊ីជម្រៅនៃពិភពហិរញ្ញវត្ថុ។

«គ្រប់គ្នាដែលធ្វើអាជីវកម្មគឺដើម្បីស្វែងរកប្រាក់ចំណេញ ហើយអ្នកនឹងមិនអាចដឹងអំពីប្រាក់ចំណេញរបស់អ្នកបានពិតប្រាកដទេ ដរាបណាអ្នកមិនមានប្រព័ន្ធគណនេយ្យត្រឹមត្រូវជាពិសេសនៅពេលអាជីវកម្មរបស់អ្នកចាប់ផ្តើមរីកចម្រើន»។

លោក Barnett មានប្រសាសន៍ថា៖«នៅពេលអ្នកមានអាជីវកម្មតូចវាមិនមែនជាបញ្ហាទេ អ្នកអាចប៉ាន់ស្មានប្រាក់ចំណូល និងចំណាយរបស់អ្នកបាន ប៉ុន្តែនៅពេលអាជីវកម្មរបស់អ្នករីកចម្រើនកាន់តែធំ វិធីតែ១គត់ដើម្បីគ្រប់គ្រងចំណូល និងចំណាយរបស់អ្នកបានត្រឹមត្រូវនិងដើម្បីធ្វើវាប្រកបដោយនិរន្តរភាពគឺត្រូវមានប្រព័ន្ធគណនេយ្យរឹងមាំ»។

ដោយមានសាស្ត្រាចារ្យដែលពោរពេញទៅដោយជំនាញវិជ្ជាជីវៈខ្ពស់មកពីជុំវិញពិភពលោក វិទ្យាស្ថាន CamEd ផ្តល់ជូននូវការអប់រំប្រកបដោយគុណភាពខ្ពស់ និងសមស្របបំផុតទៅនឹងតម្រូវការទីផ្សារហិរញ្ញវត្ថុបច្ចុប្បន្ន នៅក្នុងព្រះរាជាណាចក្រកម្ពុជា៕ ■







# ធនាគារ ស្ថាបនា រក្សាជំហររឹងមាំ ក្នុងត្រីមាសទី៣ ឆ្នាំ២០២០

ធនាគារ ស្ថាបនា ជាធនាគារជប៉ុន ដែលទទួលបាននូវសេចក្ដីទុកចិត្តយ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា ដែលកំពុងផ្ដល់នូវសេវាហិរញ្ញវត្ថុប្រកបដោយវិជ្ជាជីវៈខ្ពស់ និងភាពត្រឹមត្រូវជាក់លាក់។ ឆ្នាំ២០២០ នេះ ធនាគារអបអរសាទរនូវភាពជោគជ័យរយៈពេល២៥ឆ្នាំរបស់ខ្លួន ក្នុងព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២០ ទ្រព្យសកម្មសរុបរបស់ធនាគារ ស្ថាបនា បានកើនឡើងជាង US$ ៣០០ លាន ពី US$១,៦៧ ពាន់លាន ក្នុងឆ្នាំ២០១៩ ដល់ US$ ១,៩៦ ពាន់លាន។ ចំណែកឯប្រាក់បញ្ញើសរុបកើនឡើង ១៩,៤% ពី US$៩៨៧,៤ លាន ក្នុងឆ្នាំ ២០១៩ ដល់ US$១,១៧ ពាន់លាន។ ដោយឡែក ធនាគារក៏បានផ្ដល់ឥណទានសរុបចំនួន US$១,៤៨ ពាន់លាន។

ទោះបីមានផលប៉ះពាល់ពីវីរុសកូវីដ ១៩ ធនាគារ ស្ថាបនា បានកត់ត្រាកំណើនដ៏រឹងមាំលើប្រាក់បញ្ញើ និងឥណទាន ក៏ដូចជារក្សានូវភាពល្អប្រសើរនៃប្រាក់ចំណេញ។ នេះជាសក្ខីកម្មនៃការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ធនាគារ ស្ថាបនា ទោះបីស្ថិតក្នុងស្ថានភាពប្រឈមក្ដី។


**ស្នាក់ការកណ្ដាលថ្មីរបស់ធនាគារ ស្ថាបនា មានទីតាំងស្ថិតនៅតាមបណ្ដោយមហាវិថីព្រះនរោត្តម ក្នុងរាជធានីភ្នំពេញ។**

ធនាគារ ស្ថាបនា ជាធនាគារដែលមានបណ្ដាញសាខាធំជាងគេទី២ ក្នុងព្រះរាជាណាចក្រ ដោយមានសាខាសរុបចំនួន ១៧០ទីតាំង និងទូអេ- ធីអឹមជាង ២៣០កន្លែង នៅទូទាំងប្រទេស។ បណ្ដាញធនាគារដ៏ធំរបស់ធនាគារ ស្ថាបនា អនុញ្ញាតឱ្យអតិថិជននៅគ្រប់ខេត្តក្រុង និងតំបន់ដាច់ស្រយាល អាចប្រើប្រាស់សេវាហិរញ្ញវត្ថុ និងគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេមានប្រសិទ្ធភាពជាងមុន។

ឆ្នាំ២០២០ ជាឆ្នាំប្រកបដោយផ្លែផ្ការបស់ធនាគារ ស្ថាបនា ដោយធនាគារបានអភិវឌ្ឍធនាគារឌីជីថលរបស់ខ្លួនយ៉ាងឆាប់រហ័ស ឱ្យស្របទៅនឹងចក្ខុវិស័យយូរអង្វែង ដើម្បីក្លាយជាធនាគារឈានមុខលើវិស័យហិរញ្ញវត្ថុឌីជីថល។ មុខងារសំខាន់ៗដ៏សម្បូរបែបក្នុង Sathapana Mobile បានដាក់ឱ្យដំណើរការរួមមានដូចជាមុខងារ ដកសាច់ប្រាក់ដោយប្រើលេខកូដ បើកគណនី អនឡាញ ស្ថាបនា ផេ បណ្ណនិម្មិតវីសា ទូទាត់វិក្កយបត្រសេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងមុខងារដទៃទៀតជាច្រើន។ នៅចុងឆ្នាំនេះ ធនាគារ ស្ថាបនា នឹងសម្ពោធសាខាថ្មី ព្រមទាំងបន្ថែមចំនួនទូអេធីអឹមជាច្រើនទីតាំងទៀត សម្រាប់ភាពងាយស្រួលរបស់អតិថិជន។

ការចាប់យកនូវការផ្លាស់ប្ដូរ ជាចំណុចផ្ដោតដ៏សំខាន់មួយរបស់ធនាគារ ស្ថាបនា ដើម្បីធានាថា បច្ចេកវិទ្យាធនាគារចុងក្រោយបំផុតបានទៅដល់ដៃរបស់អតិថិជន និងធនាគារស្ថិតនៅមុខដៃគូប្រកួតប្រជែង។

ទោះបីជាផលប៉ះពាល់នៃវីរុសកូវីដ-១៩ ចាប់ផ្ដើមថមថយក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករថា ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជានឹងធ្លាក់ចុះ ៤% ក្នុងឆ្នាំ២០២០។ លើសពីនេះ ធនាគារពិភពលោក បានចេញរបាយការណ៍ថា ទេសចរណ៍ ការផលិតនាំចេញ និងសំណង់ ជាវិស័យដែលទទួលផលប៉ះពាល់ខ្លាំងជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ដោយហេតុថាវិស័យទាំងនេះបានរួមចំណែកចំនួន ៣៩,៤% នៃការងារសរុបនៅទូទាំងប្រទេស ក្នុងឆ្នាំ២០១៩។

ក្នុងពេលវេលាដ៏លំបាកនៃវីរុសកូវីដ-១៩ ធនាគារ ស្ថាបនា បានចូលរួមក្នុងការអនុវត្តនូវវិធានការដាក់ចេញរបស់ ធនាគារជាតិ នៃកម្ពុជា ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាននៃវីរុសកូវីដ១៩ លើសេដ្ឋកិច្ចជាតិ ដោយធនាគារ ស្ថាបនា បន្តជំហរ ក្នុងការផ្ដល់នូវឥណទានដល់វិស័យអាទិភាព រក្សានូវឥរិយាបថទន់ភ្លន់ចំពោះការបង់ឥណទានយឺតយ៉ាវ និងកែប្រែលក្ខខណ្ឌឥណទាន តាមលទ្ធភាពជាក់ស្ដែង៕ ■


អបអរសាទរ
ខួបអនុស្សាវរីយ៍ លើកទី
៤១
នៃការបង្កើត ធនាគារជាតិនៃកម្ពុជា ឡើងវិញ
គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី សូមសម្តែងនូវការអបអរសាទរ
ចំពោះធនាគារជាតិនៃកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍ លើកទី៤១ នៃការបង្កើតធនាគារជាតិ នៃកម្ពុជាឡើងវិញ។
យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងគោរពដឹងគុណជាទីបំផុត ចំពោះធនាគារជាតិនៃកម្ពុជា
សម្រាប់ការណែនាំ និងការបន្តគាំទ្រយ៉ាងពេញទំហឹងកន្លងមក។
ឆ្នាំ
នៅប្រទេសកម្ពុជា
មួយទសវត្សរ៍ នៃភាពរីកចម្រើន ជាមួយអតិថិជន
ធនធានមនុស្ស និងសហគមន៍
CIMB BANK

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត បន្តយកចិត្តទុកដាក់អតិថិជនខ្ពស់ក្នុងឆ្នាំ២០២០

ទោះបីជាត្រឹមត្រីមាសទី៣នៃឆ្នាំ២០២០ក៏ដោយតែវាជាឆ្នាំដ៏មមាញឹក១សម្រាប់អម្រឹតដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេ១នៅកម្ពុជា។អម្រឹតនៅតែបន្តបង្ហាញការប្ដេជ្ញាចិត្តជួយដល់ប្រជាជននៅកម្ពុជាលើគ្រប់វិស័យ។

រយៈពេលនេះអម្រឹតក៏បានជួយដល់អ្នកដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់សេដ្ឋកិច្ចពីការផ្ទុះឡើងនៃជំងឺកូវីដ១៩ខណៈស្ថាប័នមីក្រូហិរញ្ញវត្ថុកំពុងជួយផ្ដល់ដល់កសិករ និងអាជីវកម្មស្ត្រីនៅតាមជនបទ។

នាយកប្រតិបត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតលោក ដុស ឌីន មានប្រសាសន៍ថា អម្រឹតបានយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកប្រើប្រាស់សេវាឥណទាននីមួយៗក្នុងវិស័យធុរកិច្ចដែលត្រូវបានកំណត់អត្តសញ្ញាណដោយធនាគារជាតិនៃកម្ពុជាថាជាអ្នកងាយរងគ្រោះបំផុតពីផលប៉ះពាល់សេដ្ឋកិច្ចដោយសារវិបត្តិកូវីដ១៩ដូចជាវិស័យទេសចរណ៍វាយនភណ្ឌ សំណង់ និងដឹកជញ្ជូនក៏ដូចជាវិស័យកសិកម្មផងដែរ។

អម្រឹតបាននិយាយថា ខ្លួនកំពុងផ្ដល់ជំនួយដល់អតិថិជនរបស់ខ្លួនដោយផ្ដល់រយៈពេលអនុគ្រោះសងប្រាក់កម្ចី ឬបន្តការផ្ដល់ប្រាក់កម្ចីដល់អតិថិជនចំនួន១២ម៉ឺននាក់ដែលជីវភាពរបស់ពួកគេត្រូវបានរងផលប៉ះពាល់ដែលមិនធ្លាប់មានពីមុន។អម្រឹតក៏បានផ្ដល់ពេលវេលាអនុគ្រោះដល់អតិថិជននីមួយៗខណៈអាជីវកម្ម និងការងារពួកគេត្រូវបានរងផលប៉ះពាល់ដែលតំណាងឱ្យជាង១០ភាគរយនៃផលបត្រកម្ចីរបស់អម្រឹត។



លោកស្រី Estelle Darie Rousseaux អភិបាលប្រតិបត្តិរបស់អម្រឹត។

នៅក្នុងខែកក្កដា នាយកអង្គភាពពាណិជ្ជកម្មរបស់អម្រឹតលោក Alan Wee មានប្រសាសន៍ថា«ការបង្កើតកម្មវិធីកសិកម្មនៅលើកម្មវិធីទូរស័ព្ទចល័តដែលត្រូវបានគេស្គាល់ថា ជាកម្មវិធី CAMAgriMarket ដែលនាំកសិករ អ្នកទិញ អ្នកលក់ និងអ្នកពាក់ព័ន្ធទាំងអស់ជួបគ្នានៅប្រព័ន្ធឌីជីថលតែ១ដើម្បីទិញលក់ផលិតផលកសិកម្ម និងធ្វើឱ្យវិស័យកសិកម្មមាននិរន្តរភាព និងរកប្រាក់ចំណេញបាន។ទាំងអម្រឹត និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចក្ខុវិស័យរួម និងកាតព្វកិច្ចក្នុងការជួយពង្រឹងសហគមន៍កសិកម្មនៅកម្ពុជាជាមួយនឹងសេវាកម្មហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដែលចាំបាច់ដើម្បីលើកកម្ពស់ជីវភាព និងប្រាក់ចំណូលគ្រួសារតាមរយៈផលិតភាពល្អប្រសើរ»។ «កម្មវិធី CAMAgriMarket គឺជាច្រក១ដ៏ល្អសម្រាប់បម្រើដល់វិស័យកសិកម្មហើយយើងជឿជាក់ថាកម្មវិធីនេះមានសក្ដានុពលដ៏ធំធេង ដែលផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍កសិកម្មនៅទូទាំងប្រទេស»។

ក្នុងខែសីហាអម្រឹតបានបង្ហាញផលិតផលថ្មី១ដែលជំរុញដល់ការអប់រំផងដែរ។ លោក Alan Wee បាននិយាយថា ការជួយកុមារឱ្យសម្រេចក្ដីសុបិន្តការសិក្សារបស់ពួកគេគឺជាការជំរុញដ៏សំខាន់តាមរយៈ«គណនីក្មេងឆ្លាត»។

ផលិតផលនេះជាប្រភេទគណនីសន្សំរួមគ្នារវាងឪពុកម្ដាយ និងកូនក្នុងគោលបំណងបង្កើនទម្លាប់សន្សំ។យើងសង្ឃឹមថា ផែនការសន្សំនេះនឹងជួយឪពុកម្ដាយឬអាណាព្យាបាលឱ្យមានប្រាក់គ្រប់គ្រាន់ក្នុងការទំនុកបម្រុងការសិក្សាថ្នាក់ឧត្តមសិក្សារបស់កូនៗ។ ទន្ទឹមនឹងនេះយើងក៏សង្ឃឹមថាវាអាចជួយកូនៗរបស់ពួកគេទទួលបានសញ្ញាបត្រដែលជាជំហានទី១ និងបន្ទាប់មកឆ្ពោះទៅកាន់ឆាកដ៏ធំនៃវិស័យការងារ។អ្វីគ្រប់យ៉ាងអាចទៅរួចប្រសិនបើមនុស្សម្នាក់ៗមានគម្រោងនិងខិតខំប្រឹងប្រែងធ្វើវាឱ្យបាន។ ដូចនេះ ក្មេងឆ្លាតជាផលិតផលដ៏ល្អឥតខ្ចោះ១ក្នុងការបំផុសគំនិតនៃការខិតខំប្រឹងប្រែងនោះ។

ទន្ទឹមនឹងនេះ អម្រឹតបាននូវពានរង្វាន់ "ស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងការលើកម្ពស់ និងគាំទ្រស្ត្រីក្នុងអាជីវកម្មនៅកម្ពុជាប្រចាំឆ្នាំ២០២០" ផងដែរ។ លោកស្រី Estelle Darie Rousseaux អភិបាលប្រតិបត្តិរបស់អម្រឹតបានមានប្រសាសន៍ថាវាពិតជាកិត្តិយសណាស់សម្រាប់អម្រឹតដែលទទួលបាននូវពានរង្វាន់នេះ។ចាប់តាំងពីដំបូងមកម្ល៉េះអម្រឹតតែងតែទទួលស្គាល់ពីសារៈសំខាន់របស់ស្ត្រីដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់គ្រួសារនៅកម្ពុជា។

លោកស្រីថ្លែងថា៖"ជាង៩០ភាគរយនៃអតិថិជនរបស់យើងក្នុងអំឡុងពេលនៃការចាប់ផ្ដើមដំបូងនៅឆ្នាំ១៩៩០គឺជាស្ត្រី ដែលយើងបានផ្ដល់ប្រាក់កម្ចីជាក្រុមតូចៗនៅតាមភូមិ និងជាពិសេសស្ត្រីបានជឿជាក់លើសេវាយើងមុន។ សព្វថ្ងៃ អ្នកប្រើប្រាស់សេវាឥណទានរបស់អម្រឹតមាន ៦៨ភាគរយគឺជាស្ត្រីនៅគ្រប់ផ្នែក និងក្នុងអាជីវកម្មគ្រប់ប្រភេទ"។

"អម្រឹត នឹងបន្តផ្ដល់នូវដំណោះស្រាយហិរញ្ញវត្ថុដែលមានតម្លៃសមរម្យដើម្បីលើកកម្ពស់ និងគាំទ្រដល់ស្ត្រី ដែលមិនត្រឹមតែជួយបង្កើតការងារប៉ុណ្ណោះទេវាអាចថែមទាំងអាចផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍ផងដែរ។កត្តានេះនឹងជួយលើកស្ទួយជីវភាពសហគមន៍ក៏ដូចជាលើកកម្ពស់ភាពជាសហគ្រិនរបស់ស្ត្រីក្នុងប្រទេសកម្ពុជា"៕ ■

# ក្រុមហ៊ុន ផៅវ័រផ្លាស និងធនាគារ អេស៊ីលីដា សហការគ្នាដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម



ក្រុមហ៊ុន ផៅវ័រផ្លាស(ខេមបូឌា) ផ្គត់ផ្គង់គ្រឿងចក្រធុនធ្ងន់នៅកម្ពុជា។

ឥឡូវនេះ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា អាចមានជម្រើសដ៏ល្អ ក្នុងការជួលឬ ទិញគ្រឿងចក្រដើម្បីយកទៅប្រើប្រាស់សម្រាប់អាជីវកម្មបានយ៉ាងងាយស្រួល។

ក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រធុនធ្ងន់នៅកម្ពុជា គឺក្រុមហ៊ុន ផៅវ័រផ្លាស ម៉ាស៊ីនើរី ខេមបូឌា (Powerplus) បានសហការជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយបានចុះអនុស្សរណៈយោគយល់គ្នា ដើម្បីផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីប្រើប្រាស់នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដែលកំពុងរីកចម្រើន។

ធនាគារ អេស៊ីលីដា គឺជាធនាគារធំបំផុតមួយនៅកម្ពុជា ដែលមានសាខាចំនួន ២៦២ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

លោក Tho Da ប្រធានគ្រប់គ្រងក្រុមហ៊ុន ផៅវ័រផ្លាស ខេមបូឌា បានមានប្រសាសន៍ថា៖ «យើងមានមោទនភាពដែលបានសហការជាមួយធនាគារ អេស៊ីលីដា ដើម្បីផ្ដល់ហិរញ្ញប្បទាន ដល់អាជីវកម្មកម្ពុជា ដើម្បីពង្រីកការចំណាយដើមទុន និងវិនិយោគបន្ថែមទៀតក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស»។

«ខ្ញុំសង្ឃឹមថា អនុស្សរណៈនៃការយោគយល់គ្នារវាង អេស៊ីលីដា និងផៅវ័រផ្លាស នឹងធ្វើឱ្យកាន់តែមានភាពងាយស្រួលសម្រាប់ក្រុមហ៊ុនភាគីទាំង២ ដើម្បីទំនាក់ទំនង និងធ្វើការជាមួយគ្នាដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា»។

ជាមួយនឹងការផ្ដល់ជូននូវជម្រើសហិរញ្ញវត្ថុនេះ វាអនុញ្ញាតឱ្យអតិថិជនរបស់ក្រុមហ៊ុន ផៅវ័រផ្លាស ទទួលបានប្រាក់កម្ចីពីធនាគារ និងមានលទ្ធភាពពង្រីកដើមទុន ដើម្បីបានគ្រឿងចក្រធុនធ្ងន់មកប្រើប្រាស់ ដូចជា ឡានដឹកដី ឡានស្ទូច អេស្កាវ៉ាទ័រ ត្រាក់ទ័រ និងឡានឈូសឆាយ និងគ្រឿងចក្រលើកដាក់ទំនិញជាដើម។ គ្រឿងចក្រទាំងនេះ ជួយចូលរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិ ជាពិសេសនៅក្នុងវិស័យសំណង់។

«ការសហការគ្នានេះ យើងអាចធ្វើអ្វីៗបានកាន់តែច្រើនដើម្បីជួយអភិវឌ្ឍប្រទេសជាតិរបស់យើង ហើយទន្ទឹមនឹងនេះដែរ វាក៏អនុញ្ញាតឱ្យពាណិជ្ជករក្នុងស្រុក មានឧបករណ៍ធុនធ្ងន់ ដើម្បីសម្រួលដល់ដំណើរការប្រតិបត្តិការរបស់ពួកគេ»។

យោងតាមស្ថិតិផ្លូវការ ឱ្យដឹងថា វិស័យសំណង់បានទាក់ទាញការវិនិយោគសរុបចំនួន ៨,៧ពាន់លានដុល្លារក្នុងរយៈពេល ១១ខែដំបូងកាលពីឆ្នាំមុន គឺមានការកើនឡើង ៦៧ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ។ ភាពជាដៃគូរវាងក្រុមហ៊ុន ផៅវើផ្លាស និងធនាគារ អេស៊ីលីដា នឹងអនុញ្ញាតឱ្យម្ចាស់អាជីវកម្មខ្នាតតូចមានឱកាសកាន់តែច្រើនដើម្បីបម្រើដល់វិស័យដែលកំពុងរីកចម្រើន១នេះ។

ក្រុមហ៊ុន ផៅវ័រផ្លាស ជាក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រធុនធ្ងន់សម្រាប់វិស័យដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅកម្ពុជានេះ។

«យើងផ្ដល់ជូននូវផលិតផល Powerplus ឈានមុខគេនៅលើទីផ្សារដូចជា ឡានដឹកទំនិញធុនធ្ងន់ ឡានដឹកស៊ីម៉ងត៍ ឡានស្ទូច ឡានឈូសឆាយ ត្រាក់ទ័រ និងគ្រឿងចក្រជាច្រើនទៀត។ អាជីវកម្មរបស់យើងផ្ដោតលើគ្រឿងចក្រដែលអ្នកអាចជឿទុកចិត្តបាន ហើយការពេញចិត្តរបស់អតិថិជនគឺមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន ផៅវើផ្លាស»។

លោក Da បន្តថា៖«យើងផ្ដល់ជូនតម្រូវការជាច្រើន មិនត្រឹមតែការលក់ឧបករណ៍សំណង់ដែលមានគុណភាពប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ជួយអតិថិជនរបស់យើងដោយផ្ដល់នូវហិរញ្ញវត្ថុដល់ការទិញឧបករណ៍ធុនធ្ងន់ ហើយយើងគាំទ្រពួកគេយ៉ាងពេញទំហឹង»។

លោក Dennis Tan តំណាងក្រុមហ៊ុន Powerplus បានថ្លែងថា ទន្ទឹមនឹងការលក់គ្រឿងចក្រ ក្រុមហ៊ុនក៏ផ្ដល់ជូននូវសេវាកម្មថែទាំ ជាមួយនឹងគ្រឿងបន្លាស់ដែលមានស្រាប់ក្នុងស្តុក ដើម្បីគាំទ្របណ្ដាញអ្នកចែកចាយរបស់ក្រុមហ៊ុន ផៅវើសផ្លាស។ លោកបន្ថែមថា ម្ចាស់សហគ្រាសធុនតូច និងមធ្យមភាគច្រើន ចូលចិត្តបង់ថ្លៃជួលប្រចាំខែសម្រាប់ប្រើប្រាស់ឧបករណ៍ធុនធ្ងន់ ជាជាងទិញជាម្ចាស់កម្មសិទ្ធិ។

«ជាមួយនឹងការអនុវត្តកាតព្វកិច្ចបង់រំលស់ប្រចាំខែ សម្រាប់ប្រើប្រាស់នូវឧបករណ៍ទាំងនោះ យើងសង្ឃឹមថា នឹងអាចជួយប្រជាជនកម្ពុជាឱ្យក្លាយជាម្ចាស់កម្មសិទ្ធិគ្រឿងចក្រពេញលេញ និងប្រើប្រាស់គ្រឿងចក្ររបស់យើងជាសម្បត្តិរបស់ពួកគេដើម្បីបង្កើតប្រាក់ចំណូលបន្ថែម។ យើងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្ររបស់ធនាគារ អេស៊ីលីដា»៕ ■


អបអរសាទរខួបលើកទី
៤១
នៃការបង្កើតឡើងវិញរបស់ធនាគារជាតិនៃកម្ពុជា
ធនាគារភីភីស៊ីប៊ែង សូមចូលរួមអបអរសាទរក្នុងឱកាស **គម្រប់ខួបលើកទី ៤១** នៃការបង្កើតឡើងវិញរបស់ **ធនាគារជាតិនៃកម្ពុជា**
យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ កិច្ចខិតខំប្រឹងប្រែងដ៏ឆ្នើមរបស់ធនាគារជាតិនៃកម្ពុជា ហើយយើងក៏មានមោទនភាពក្នុងការគាំទ្រ រាល់ការងាររបស់ធនាគារជាតិនៃកម្ពុជា ដែលចូលរួមចំណែកឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយភាពរីកចម្រើនឥតឈប់ឈរ។
PPCBank